**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

លេខ........០១៤........អ. ស. ហ..ប្រក

# ប្រកាស

# ស្តីពី

# សេវាសាធារណៈរបស់និយ័តករធានារ៉ាប់រងកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញបទបញ្ជាលេខ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ



អគារ១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩៩ ៧០០
#168F, Street 598, Sangkat Chrang Chamres 1, Khan Russei Keo, Phnom Penh, Cambodia
Phone: (+855) 23 999 700

- បានឃើញប្រកាសលេខ ៥២៦ សហវ.ប្រក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ប្រភព និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់និយ័តករធានារ៉ាប់រងកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់និយ័តករធានារ៉ាប់រងកម្ពុជា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់ប្រភេទសេវាសាធារណៈ កម្រៃសេវាសាធារណៈ បែបបទ នីតិវិធី និងការចាត់ចែងចំណូលពីសេវាសាធារណៈរបស់និយ័តករធានារ៉ាប់រងកម្ពុជា "**ន.ធ.ក.**" ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីធានាប្រសិទ្ធភាព និងសក្តិសិទ្ធភាព នៃកិច្ចដំណើរការរបស់ **ន.ធ.ក.**។

## ជំពូកទី២

## ប្រភេទសេវាសាធារណៈ និងកម្រៃសេវាសាធារណៈ

**ប្រការ២ .-**

ប្រភេទសេវាសាធារណៈ និងកម្រៃសេវាសាធារណៈរបស់ **ន.ធ.ក.** ត្រូវបានកំណត់ដូចខាងក្រោម÷

| ល.រ. | បរិយាយ | កម្រៃសេវារដ្ឋបាល/ កម្រៃអាជ្ញាបណ្ណ | រយៈពេលផ្តល់សេវា | សុពលភាព |
|---|---|---|---|---|
| ១ | សេវាផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល ២០ ០០០ ០០០ រៀល | ៩០ ថ្ងៃ | ៥ ឆ្នាំ |
| | | កម្រៃអាជ្ញាបណ្ណ ៥០ ០០០ ០០០ រៀល/ឆ្នាំ | | |
| ២ | សេវាផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច | កម្រៃសេវារដ្ឋបាល ១ ០០០ ០០០ រៀល | ៩០ ថ្ងៃ | អចិន្ត្រៃយ៍ |
| | | កម្រៃអាជ្ញាបណ្ណ ៦ ០០០ ០០០ រៀល/ឆ្នាំ | | |
| ៣ | សេវាផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនជើងសាធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល ២ ០០០ ០០០ រៀល | ៤៥ ថ្ងៃ | ១ ឆ្នាំ |

| | | | | |
|---|---|---|---|---|
| | | កម្រៃអាជ្ញាបណ្ណ<br>៤ ០០០ ០០០ រៀល | | |
| ៤ | សេវាផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល<br>២ ០០០ ០០០ រៀល | ៤៥ ថ្ងៃ | ៣ ឆ្នាំ |
| | | កម្រៃអាជ្ញាបណ្ណ<br>៣ ០០០ ០០០ រៀល | | |
| ៥ | សេវាផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល<br>១ ០០០ ០០០ រៀល | ៤៥ ថ្ងៃ | ៣ ឆ្នាំ |
| | | កម្រៃអាជ្ញាបណ្ណ<br>៣ ០០០ ០០០ រៀល | | |
| ៦ | សេវាផ្តល់វិញ្ញាបនបត្រសាខាក្នុងស្រុករបស់ក្រុមហ៊ុនធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល<br>១ ០០០ ០០០ រៀល/ សាខា | ៤៥ ថ្ងៃ | ៥ ឆ្នាំ |
| ៧ | សេវាផ្តល់ការអនុញ្ញាតផ្លាស់ប្តូរទីតាំងគ្រឹះស្ថានធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល<br>៨០០ ០០០ រៀល/ទីតាំង | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ៨ | សេវាផ្តល់ការអនុញ្ញាតផ្លាស់ប្តូរភាគទុនិក | កម្រៃសេវារដ្ឋបាល<br>៨០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ៩ | សេវាផ្តល់ការអនុញ្ញាតផ្លាស់ប្តូរ ឬតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល | កម្រៃសេវារដ្ឋបាល<br>៨០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ១០ | សេវាផ្តល់ការអនុញ្ញាតតែងតាំងអគ្គនាយកក្រុមហ៊ុន | កម្រៃសេវារដ្ឋបាល<br>៨០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ១១ | សេវាផ្តល់ការអនុញ្ញាតលក់ផលិតផលធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល<br>១ ០០០ ០០០ រៀល/ផលិតផល | ២០ ថ្ងៃ | អចិន្ត្រៃយ៍ |
| ១២ | សេវាផ្តល់ការកែប្រែផលិតផលធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល<br>៥០០ ០០០ រៀល/ផលិតផល | ២០ ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៣ | សេវាផ្តល់ការអនុញ្ញាតបន្ថយ ឬបង្កើនដើមទុន | កម្រៃសេវារដ្ឋបាល<br>១ ០០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ១៤ | សេវាផ្តល់ការអនុញ្ញាតតែងតាំងក្រុមហ៊ុនសវនកម្មឯករាជ្យ | កម្រៃសេវារដ្ឋបាល<br>៤០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |

| | | | | |
|---|---|---|---|---|
| ១៥ | សេវាផ្តល់ការបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្មរបស់គ្រឹះស្ថានធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល ១០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ១៦ | សេវាពិគ្រោះយោបល់លើការបកស្រាយខ្លឹមសារច្បាប់ និងបទប្បញ្ញត្តិស្តីពីការធានារ៉ាប់រង ឬនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល ៨០០ ០០០រៀល/ម៉ោង | ជូនដំណឹងមុន ៣ ថ្ងៃ | មួយលើក |
| ១៧ | សេវាផ្តល់បទឧទ្ទេសនាមស្តីពីវិស័យធានារ៉ាប់រង ក្នុងអង្គសិក្ខាសាលា ឬពិធីផ្សេងៗ | កម្រៃសេវារដ្ឋបាល ១ ០០០ ០០០ រៀល/ដង | ជូនដំណឹងមុន ៣ ថ្ងៃ | មួយលើក |
| ១៨ | សេវាផ្តល់ការអនុញ្ញាតតែងតាំង ឬផ្លាស់ប្តូរអ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង | កម្រៃសេវារដ្ឋបាល ៨០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ១៩ | សេវាផ្តល់ការអនុញ្ញាតបង្កើតគណៈកម្មការសវនកម្ម | កម្រៃសេវារដ្ឋបាល ៨០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ២០ | សេវាផ្តល់ការអនុញ្ញាតបង្កើតគណៈកម្មការវិនិយោគ | កម្រៃសេវារដ្ឋបាល ៨០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ២១ | សេវាផ្តល់ការអនុញ្ញាតចុះកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត ឬការកែសម្រួលកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត | កម្រៃសេវារដ្ឋបាល ២ ០០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |
| ២២ | សេវាផ្តល់ការអនុញ្ញាតលើការបែងចែកភាគលាភ | កម្រៃសេវារដ្ឋបាល ២ ០០០ ០០០ រៀល | ២០ ថ្ងៃ | រហូតមានការអនុញ្ញាតថ្មី |

## ជំពូកទី៣

## នីតិវិធីនៃការស្នើសុំ និងការបង់កម្រៃសេវាសាធារណៈ

**ប្រការ៣ .-**

បុគ្គលស្នើសុំសេវាសាធារណៈរបស់ **ន.ធ.ក.** អាចស្នើសុំតាមរយៈច្រកចេញចូលតែមួយរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ “**អ.ស.ហ.**” ឬតាមរយៈគេហទំព័រ របស់ **ន.ធ.ក.**។

**ប្រការ៤ .-**

បុគ្គលស្នើសុំសេវាសាធារណៈរបស់ **ន.ឆ.ភ.** ត្រូវបង់កម្រៃសេវាសាធារណៈចូលគណនីរបស់ **ន.ឆ.ភ.**។

## ជំពូកទី៤

## ការផ្សព្វផ្សាយ និងការផ្តល់សេវាគាំទ្រ

**ប្រការ៥ .-**

**ន.ឆ.ភ.** ត្រូវបិទផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈនូវប្រកាសនេះ នៅនឹងកន្លែងផ្តល់សេវា ឬតាមបណ្តាញព័ត៌មាន ជាពិសេសនៅច្រកចេញ-ចូលតែមួយ។

**ន.ឆ.ភ.** ត្រូវរៀបចំទីកន្លែងផ្តល់សេវាដែលមានលក្ខណៈជាច្រកចេញ-ចូលតែមួយ និងមានមន្ត្រីប្រចាំការនៅទីកន្លែងដែលបានកំណត់ជាក់លាក់ ដើម្បីទទួលបម្រើសេវាជូនសាធារណជនឱ្យបានទាន់ពេលវេលាតាមការកំណត់។

**ន.ឆ.ភ.** ត្រូវរៀបចំឱ្យមានទីកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដាសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

## ជំពូកទី៥

## ការគ្រប់គ្រងចំណូលពីសេវាសាធារណៈ

**ប្រការ៦ .-**

**ន.ឆ.ភ.** មានភារកិច្ចប្រមូល គ្រប់គ្រង និងចាត់ចែងចំណូលពីសេវាសាធារណៈដែលប្រមូលបានស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៧ .-**

**ន.ឆ.ភ.** ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណូលពីសេវាសាធារណៈប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់។

**ប្រការ៨ .-**

ប្រភេទសេវាសាធារណៈ និងកម្រៃសេវាសាធារណៈ បានកំណត់នៅក្នុងប្រការ២ នៃប្រកាសនេះ អាចកែប្រែបាន តាមការចាំបាច់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង បុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៩ កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តមនិងលោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សា-អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ